**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៦៥២៤ កសក

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៧

**សូមជម្រាបជូន**

- ឯកឧត្តម លោក លោកស្រី ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

**កម្មវត្ថុ** ៖ សំណើយកចិត្តទុកដាក់អនុវត្តតាមការណែនាំលើការរៀបចំលិខិតតាមទម្រង់ណែនាំរបស់ក្រសួង។

**យោង** ៖ លិខិតលេខ៤៩១ កសក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប ឯកឧត្តម លោក លោកស្រី ជ្រាបថា ដើម្បីឱ្យមានការឯកភាពគ្នាលើទម្រង់លិខិតរដ្ឋបាលរបស់ក្រសួងនោះ ក្រសួងបានធ្វើការណែនាំតាមទម្រង់ដែលបានជូនភ្ជាប់តាមលិខិតលេខ៤៩១ កសក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ រួចហើយ។ ក្នុងនោះគំរូលិខិតចំនួន ០៩ ដែលណែនាំឱ្យតាក់តែងដោយប្រើប្រាស់ហ្វុងអក្សរ Khmer OS Battambang គម្រឹមគែមខាងឆ្វេង (Left) ទុក ២,៥ស.ម និងខាងស្តាំ (Right) ទុក ១,៥ស.ម ។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោក លោកស្រី យកចិត្តទុកដាក់អនុវត្តតាមការណែនាំឱ្យបានឯកភាពគ្នាលើទម្រង់លិខិត (សូមជូនភ្ជាប់មកនូវគំរូសាជាថ្មី) តាមការគួរ។

សូម ឯកឧត្តម លោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**ត.ប រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គលេខាធិការ**

**ចម្លងជូនៈ**
-ថ្នាក់ដឹកនាំក្រសួង
-ខុទ្ទកាល័យរដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-ឯកសារ កាលប្បវត្តិ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

## កំណត់សម្គាល់

**I.ទម្រង់នៃការតាក់តែងលិខិតស្នាមរដ្ឋបាល បានរៀបចំចំនួន០៩ប្រភេទ ជាគំរូដូចខាងក្រោម៖**

១.លិខិតទូលថ្វាយព្រះករុណាព្រះមហាក្សត្រ

២.លិខិតគោរពជូនសម្តេចនាយករដ្ឋមន្ត្រី

៣.លិខិតគោរពជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី

៤.លិខិតគោរពជូនឯកឧត្តមទេសរដ្ឋមន្ត្រី

៥.លិខិតគោរពជូនឯកឧត្តមរដ្ឋមន្ត្រី

៦.លិខិតជម្រាបជូនស្ថាប័នថ្នាក់ទាបជាងក្រសួង

៧.លិខិតជម្រាបជូនអង្គភាពក្រោមឱវាទ

៨.របាយការណ៍ផ្ញើជូនក្រសួង

៩.លិខិតអញ្ជើញផ្សេងៗ។

ឧទាហរណ៍៖

១.លិខិតទៅព្រះមហាក្សត្រ ប្រើពាក្យ សូមក្រាបបង្គំទូលថ្វាយ "**ព្រះករុណា ព្រះបាទសម្តេច**............." សរសេរ២ជួរ ខ្លឹមសារឃ្លាចុងក្រោយ សូម "**ព្រះករុណា ព្រះបាទសម្តេច**............. " ទ្រង់ព្រះមេត្តាទទួលនូវគារវភក្តីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំ។

២.លិខិតទៅសម្តេច ប្រើពាក្យ សូមគោរពជូន "**សម្តេច**........................" សរសេរ២ជួរ ខ្លឹមសារឃ្លាចុងក្រោយ "សូម **សម្តេច**.................... មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។"

៣. លិខិតទៅឯកឧត្តម ឬលោកជំទាវឧបនាយករដ្ឋមន្ត្រី ឬទេសរដ្ឋមន្ត្រី ប្រើពាក្យ **សូមគោរពជូន** ដូចគ្នា ឃ្លាចុងក្រោយ សូម ឯកឧត្តម ឬលោកជំទាវឧបនាយករដ្ឋមន្ត្រី ឬឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

៤. លិខិតទៅឯកឧត្តម ឬលោកជំទាវរដ្ឋមន្ត្រីថ្នាក់ស្មើគ្នា ប្រើពាក្យ **គោរពជូន** ឃ្លាចុងក្រោយ សូម ឯកឧត្តម ឬលោកជំទាវរដ្ឋមន្ត្រី មេត្តាទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

៥. លិខិតពីថ្នាក់ខ្ពស់ទៅថ្នាក់ទាបជាង ប្រើពាក្យ **ជម្រាបជូន** ឯកឧត្តម ឬលោក លោកស្រីប្រធាន ឃ្លាចុងក្រោយ សូម...........មេត្តាទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

៦. ករណីមានការសម្រេចពីឯកឧត្តមរដ្ឋមន្ត្រីហើយៗ លិខិតជម្រាបអង្គភាពក្រោមឱវាទក្រសួង ប្រើពាក្យ ជម្រាបជូន...............ដោយយោងចំណារឯកឧត្តមរដ្ឋមន្ត្រី ចុះថ្ងៃទី...... ខែ....... ឆ្នាំ..... ឃ្លាចុងក្រោយ សូម........មេត្តាទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។ ការចុះហត្ថលេខា ត្រឹមអគ្គលេខាធិការដ្ឋាន។

៧.របាយការណ៍ថ្នាក់ដឹកនាំក្រសួង ឬប្រធានអង្គភាពដែលក្រសួងបានចាត់ឱ្យទៅចូលរួមកិច្ចប្រជុំ ពិធីផ្សេងៗ ឬចុះតាមមូលដ្ឋាន ស្នើរៀបចំដោយប្រើប្រាស់ក្បាលលិខិត (Logo) ក្រសួង ហើយឃ្លាចុងក្រោយ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាប និងផ្តល់នូវអនុសាសន៍ណែនាំដោយក្តីអនុគ្រោះ។

៨.លិខិតអញ្ជើញ យើងប្រើពាក្យ **សូមគោរពអញ្ជើញ ឬ សូមអញ្ជើញ** ចុះបន្ទាត់គ្រែ **ឯកឧត្តម ឬ លោក**...................... ចុះបន្ទាត់ **ដើម្បីចូលរួម៖**.............. ចុះបន្ទាត់ **ទីកន្លែង៖**........... ចុះបន្ទាត់ **កាលបរិច្ឆេទ៖**..........ចុះបន្ទាត់ **ចុះហត្ថលេខាដោយអគ្គលេខាធិការតាមបញ្ជារដ្ឋមន្ត្រី។** ករណីអញ្ជើញក្រៅក្រសួង ចុះហត្ថលេខាដោយ **ឯកឧត្តមរដ្ឋមន្ត្រី**។

II.ការកំណត់រឹម(គែម)នៅក្នុងលិខិត (Page Setup Margins) ដូចខាងក្រោម៖

-ខាងឆ្វេង (Left) ទុក ២.៥សម

-ខាងស្តាំ (Right) ទុក ១.៥សម

-ខាងលើ (Top) ទុក ១សម

-ខាងក្រោម (Bottom) ទុក ១.៥សម

III. ចំពោះប្រភេទក្រដាស គឺប្រភេទ A4 (Page Setup ➡ Paper ➡ Paper Size យក A4) និងមានក្បាលលិខិត (Logo) ជាគំរូភ្ជាប់មកជាមួយ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៤៩១ កសក

រាជធានីភ្នំពេញ, ថ្ងៃទី.១៧...ខែ.សីហា.ឆ្នាំ ២០១៧

**ជម្រាបជូន**

-ឯកឧត្តម លោក លោកស្រីប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

**កម្មវត្ថុ** ៖ការរៀបចំលិខិតតាមទម្រង់ណែនាំរបស់ក្រសួងឱ្យបានឯកភាពគ្នា។

**ជូនភ្ជាប់** ៖គំរូលិខិតចំនួន..........................................................................................០៩ច្បាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងជូនភ្ជាប់ខាងលើ ខ្ញុំសូមជម្រាប ឯកឧត្តម លោក លោកស្រីប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងជ្រាបថា ដើម្បីចៀសវាងនូវការប្រើពាក្យ ទម្រង់លិខិតស្នាម ទំហំ និងហ្វុងអក្សររដ្ឋបាលខុសៗគ្នាតាមអង្គភាពនីមួយៗ និងដើម្បីឱ្យមានការឯកភាពលើទម្រង់លិខិតរដ្ឋបាលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំសូមឯកឧត្តម លោក លោកស្រីប្រធានអង្គភាពចាត់ចែងឱ្យការិយាល័យរដ្ឋបាល នៃអង្គភាពនីមួយៗរៀបចំលិខិតតាមទម្រង់ណែនាំរបស់ក្រសួងដូចមានជូនភ្ជាប់មកជាមួយចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោក លោកស្រីប្រធានអង្គភាពជ្រាប និងអនុវត្តតាមខ្លឹមសារខាងលើឱ្យបានសមស្របតាមការគួរ។

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វង្ស សាខុន**

**ចម្លងជូន៖**
-ថ្នាក់ដឹកនាំក្រសួង
-ខុទ្ទកាល័យរដ្ឋមន្ត្រី
"ដើម្បីជ្រាប"
-ឯកសារ កាលប្បវត្តិ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320